ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**អាជ្ញាធរទន្លេសាប**

គណៈកម្មាធិការលទ្ធកម្ម

លេខ : ០៤៨.......អទស.សជណ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃការងារជួសជុលរថយន្ត ប្រចាំឆ្នាំ ២០១៨

**អាជ្ញាធរទន្លេសាប** (ក្រសួងធនធានទឹក និងឧតុនិយម) សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុនក្នុងស្រុក (គិតទាំងសហគ្រាសឯកត្តបុគ្គល) ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថាៈ **អាជ្ញាធរទន្លេសាប** (ក្រសួងធនធានទឹក និងឧតុនិយម) នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ សម្រាប់ការងារជួសជុលរថយន្ត ប្រចាំឆ្នាំ២០១៨ របស់**អាជ្ញាធរទន្លេសាប** ។

ក្រុមហ៊ុនដែលមានចំណាប់អារម្មណ៍អាចទាក់ទងនៅអង្គភាពលទ្ធកម្ម នៃ**អាជ្ញាធរទន្លេសាប** ដែលមានអាសយដ្ឋានលេខ៥៧៦ ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ ២០១៨ តទៅ រៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទំនាក់ទំនងលេខ 023 727 454 និង 080 5555 80 ) ។

កាលបរិច្ឆេទឈប់ទទួលពាក្យ នៅម៉ោង១០ និង០០នាទីព្រឹក ថ្ងៃទី ០៩ ខែមីនា ឆ្នាំ ២០១៨ ។

ការបើកកញ្ចប់ឯកសារដេញថ្លៃ នឹងប្រព្រឹត្តទៅ នៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើវេលាម៉ោង ១០ និង០០នាទីព្រឹក ថ្ងៃទី ០៩ ខែមីនា ឆ្នាំ ២០១៨ ។

ក្រុមហ៊ុនដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬ មានប្រភពតែមួយ អាចដាក់ឯកសារបានតែមួយគត់ ។

ក្រុមហ៊ុនដែលមានបំណងចូលរួមដេញថ្លៃ សូមទាក់ទងជាមួយអង្គភាពលទ្ធកម្ម **អាជ្ញាធរទន្លេសាប** (ក្រសួងធនធានទឹក និងឧតុនិយម ) ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាននានា ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃពុធ ៧រោច ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៨

ជ. **ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ហៀល គូនី**

ចម្លងជូន :

- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ